**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០២៣/០៨ របក.អគគ**

## របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំខែ កក្កដា ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កក្កដា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមាន អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេច បាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

-បានរៀបចំសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមគម្រោងកិច្ចសហប្រតិបត្តិការ ជាមួយអង្គការ GTZ

-បានទទួលរបាយការណ៍ ប្រចាំឆ្នាំពីប្រធានតុលាការក្រុងភ្នំពេញ ស្តីពីសកម្មភាពការងារ គិតពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨

-បានទទួលលិខិតអញ្ជើញពីមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ដោយអញ្ជើញមន្ត្រីជំនាញមួយរូបចូលរួមជាវាគ្មិនកិត្តិយស ក្នុងកម្មវិធីសំណេះសំណាលតាមទូរស័ព្ទក្រោមប្រធានបទ “ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ”

-បានទទួលលិខិតអញ្ជើញពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយអញ្ជើញចូលរួមសិក្ខាសាលាស្តីពីការ រៀបចំគម្រោងស្នើសុំហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការពីរដ្ឋាភិបាលជប៉ុន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៨

-បានទទួលរបាយការណ៍ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីរបាយការណ៍បូកសរុបលទ្ធផលអនុវត្តការងារក្នុងខែមេសា ឆ្នាំ២០០៨ និងទិសដៅបន្តកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨។

**ខ. ការងារកំណែទម្រង់**

-បន្តប្រជុំរៀបចំសូចនាករតាមក្រុមគម្រោងទាំងអស់នៃអង្គភាពគ្រប់គ្រងគម្រោង

-ពិភាក្សាជាមួយតំណាង UNDP លើការបញ្ចូលទិន្នន័យគម្រោង ១.១.១ និងចុះជួបអង្គការ អ្នកផ្តល់ការ បណ្តុះបណ្តាលមួយចំនួន នៅភ្នំពេញ

-ចុះជួបតុលាការខេត្តកំពង់ចាមលើការងារតុលាការគំរូ។

**គ. ផ្សេងៗ**

-ចូលរួមប្រជុំអន្តរក្រសួងលើកទី១ ដោយពិភាក្សាអំពីនីតិវិធី នៃការតាក់តែងច្បាប់ និងសេចក្តីព្រាងអនុក្រឹត្យផ្សេងៗ ដូចជាអនុក្រឹត្យបង្កើតសាលាភូមិន្ទសារការី អាជ្ញាសាលាជាអាទិ៍។

**២-សន្និដ្ឋាន**

ក្នុងខែ កក្កដា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានបន្តការយ៉ាងសកម្ម លើការរៀបចំប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ និងបានត្រៀមខ្លួនសម្រាប់អនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-បន្តអនុវត្តគម្រោងតុលាការគំរូ ជាពិសេសធ្វើសម្ព័ន្ធចម្លើយ និងសំណួរសម្រាប់ តុលាការក្រុងភ្នំពេញ តុលាការខេត្តកំពង់ចាម តុលាការខេត្តកណ្តាល និងតុលាការខេត្តបន្ទាយមានជ័យ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-អនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ អទឈ

-ជម្រុញឱ្យអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលមជ្ឈត្តការ ពាណិជ្ជ-កម្មចេញបានឆាប់។

រាជធានី ភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៨
អ្នកធ្វើរបាយការណ៍

ហ៊្សឹង សុកុល

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង